ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ព្រឹទ្ធសភា
អគ្គលេខាធិការដ្ឋាន

# របាយការណ៍
# ស្តីពី
# លទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៤

នៅក្នុងខែតុលានេះ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបំពេញការងារលើគ្រប់វិស័យ ដើម្បីផ្តល់សេវាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ក្នុងការអនុវត្តមុខងាររបស់ខ្លួនប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ដោយទទួលបានលទ្ធផលដូចខាងក្រោម៖

## I-លទ្ធផលការងារសម្រេចបានលើមុខងារទាំង៥៖

### ១-មុខងារនីតិកម្ម

- បានរៀបចំចាត់ចែងប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ១លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បី៖
  - ១- ពិនិត្យ និងសម្រេចលើរបាយការណ៍សង្ខេបស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។
  - ២- កំណត់កាលបរិច្ឆេទ របៀបវារៈ និងសមាសភាពលេខាធិការសម័យប្រជុំព្រឹទ្ធសភាលើកទី២ នីតិកាលទី៥ និង
  - ៣- ផ្សេងៗ។
- បានរៀបចំចាត់ចែងបើកសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ដើម្បីស្តាប់របាយការណ៍សង្ខេបរបស់គណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី លទ្ធផល និងសកម្មភាពការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។

### ២-មុខងារតំណាង

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖
  - ❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** នៃព្រះរាជាណាចក្រកម្ពុជា បានអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានីភ្នំពេញ ចំនួន ៣លើក រួមមាន៖

- អញ្ជើញចូលរួមថ្វាយព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី១៩ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញទទួលព្រះរាជដំណើររបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ជាទីគោរពសក្ការៈដ៏ខ្ពង់ខ្ពស់បំផុត ស្តេចយាងនិវត្តន៍ពីការចូលរួមកិច្ចប្រជុំកំពូលហ្វ្រង់កូហ្វូនី លើកទី១៩ នៅទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ និង
- អញ្ជើញនាំយកនូវគ្រឿងសក្ការបូជា បច្ច័យ ទេយ្យទាន និងគ្រឿងឧបភោគ ប្រគេនព្រះសង្ឃចំនួន ២៥០អង្គ នៅវត្តមុន្នីសុវណ្ណ ហៅវត្តចំពុះក្អែក ស្ថិតក្នុងខណ្ឌច្បារអំពៅ រាជធានីភ្នំពេញ។

❖ សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអញ្ជើញចូលរួមក្នុងពិធីនានា នៅរាជធានីភ្នំពេញ ចំនួន ៤លើក រួមមាន៖

- អញ្ជើញចូលរួមព្រះរាជពិធីសាសនាខួបលើកទី២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះបរមរាជវាំង។
- អញ្ជើញចូលរួមព្រះរាជពិធីមហាមីទ្ទិញខួបលើកទី២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
- អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ និង
- អញ្ជើញប្រទានភ្លើងបូជាសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅបរិវេណមុខវត្តបទុមវតី រាជធានីភ្នំពេញ។

❖ ឯកឧត្តម **ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** បានអញ្ជើញដឹកនាំកិច្ចប្រជុំ និងចូលរួមក្នុងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ចំនួន ៩លើក រួមមាន៖

- អញ្ជើញដឹកនាំកិច្ចប្រជុំជាមួយគណៈប្រតិភូអមដំណើរ ដើម្បីពិនិត្យលើកម្មវិធី និងឯកសារពាក់ព័ន្ធ នៃដំណើរទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រ នៃបុរីក្សត្រលុចសំបួ។
- អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ថ្វាយកម្រងផ្កាគោរព

ព្រះវិញ្ញាណក្ខន្ធ ព្រះករុណាព្រះបាទសម្តេចព្រះ **នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរមរតនកោដ្ឋ"** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។

- អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធីខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។
- អញ្ជើញចូលរួមព្រះរាជពិធីមហាមីទ្ទិញខួបលើកទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
- អញ្ជើញចូលរួមក្នុងពិធីអបអរសាទរខួប២០ឆ្នាំ នៃកម្ពុជាចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា នៅសណ្ឋាគារសុខាភ្នំពេញ។
- អញ្ជើញចូលរួមពិធីបូជាសព **ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម នៅបរិវេណមុខវត្តបទុមវតី រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- អញ្ជើញគោរពវិញ្ញាណក្ខន្ធសព**ឧបាសិកា ប៊ួយ ហ៊ាន** ត្រូវជាម្តាយបង្កើតរបស់ **លោក អ៊ី ឆភីរុណ** ប្រធាននាយកដ្ឋានគ្រប់គ្រងអគារ សារពើភណ្ឌ និងសំណង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់អូរបែកក្អម ខណ្ឌសែនសុខ រាជធានីភ្នំពេញ និង
- អញ្ជើញចូលរួមរំលែកទុក្ខ និងគោរពវិញ្ញាណក្ខន្ធសព **កញ្ញា សេង ច័ន្ទវណ្ណា** ត្រូវជាកូនស្រីបង្កើតរបស់ **លោក សេង ជៀន** ចៅសង្កាត់ស្ពោរ នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ស្ពោរ ខណ្ឌកំបូល រាជធានីភ្នំពេញ។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា បាន៖**

- អញ្ជើញដឹកនាំ និងចូលរួមកិច្ចប្រជុំ ចំនួន ៣លើក៖
    - អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ព្រឹទ្ធសភា ចំនួន ១លើក និងចូលរួមសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ ចំនួន ១លើក និង

- អញ្ជើញដឹកនាំកិច្ចប្រជុំផ្ទៃក្នុងក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី២ នៅបន្ទប់ប្រជុំរបស់ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា។

▪ អញ្ជើញចូលរួមក្នុងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន ៦លើក រួមមាន៖

- អញ្ជើញចូលរួមជាកិត្តិយសក្នុងព្រះរាជពិធីថ្វាយព្រះពរ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសព្រះរាជពិធីខួបទី២០ នៃការគ្រងព្រះបរមសិរីរាជសម្បត្តិ នៅព្រះទីនាំងទេវាវិនិច្ឆ័យ ព្រះបរមរាជវាំង។
- អញ្ជើញចូលរួមព្រះរាជពិធីមហាមីទ្ទិញខួបលើកទី២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅព្រះពន្លាកិត្តិយសខាងលើព្រះទីនាំងចន្ទច្ឆាយា។
- អញ្ជើញចូលរួមអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** ប្រធានព្រឹទ្ធសភា ក្នុងពិធីបូជាសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅបរិវេណមុខវត្តបទុមវតី រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម និង
- ដឹកនាំផ្តើមធ្វើពិធីបុណ្យកឋិនទានសាមគ្គីដើម្បីដង្ហែទៅវេរប្រគេនព្រះសង្ឃដែលគង់ចាំព្រះវស្សាអស់កាលត្រីមាស ក្នុងពុទ្ធសីមា វត្តនិគ្រោធធម្មាសុខារាម ហៅវត្តអន្លង់ជ្រៃ ស្ថិតក្នុងឃុំច្បារអំពៅ ស្រុកបាធាយ ខេត្តកំពង់ចាម។

❖ សមាជិក សមាជិកាព្រឹទ្ធសភា បាន៖

▪ អញ្ជើញថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ "ព្រះបរម**

**រតនកោដ្ឋ** " គម្រប់ខួប១២ឆ្នាំ ដឹកនាំដោយ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។

- បានអញ្ជើញចូលរួមអបអរសាទរខួបលើកទី៣១ នៃទិវាប្រកាសរដ្ឋធម្មនុញ្ញ ២៤ កញ្ញា និងព្រះរាជពិធីសម្ពោធវិមានរដ្ឋធម្មនុញ្ញ ក្រោមព្រះរាជាធិបតីភាពដ៏ខ្ពង់ខ្ពស់បំផុតរបស់ **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា នៅសួនច្បារខាងលិចវិមានឯករាជ្យ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ស្តីពី សេចក្តីព្រាង " **ធម្មនុញ្ញសន្តិភាពដើម្បីមនុស្សជាតិ និងភពផែនដី** " និងស្តាប់បទបាឋកថា ពិសេសអំពី " **បទពិសោធន៍ដឹកនាំ និងចក្ខុវិស័យសន្តិភាព** " ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នៅវិមាន៧មករា។
- អញ្ជើញចូលរួមអបអរសាទរពិធីសំណេះសំណាល និងបំពាក់កន្សែងយុវជនកាកបាទក្រហមកម្ពុជា ចំនួន ៤,៧៤២នាក់ មកពីគ្រឹះស្ថានឧត្តមសិក្សា ចំនួន ២៥ ក្នុងរាជធានីភ្នំពេញ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី ហ៊ុន សែន** ប្រធានកាកបាទក្រហមកម្ពុជា និង**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា និង**លោកជំទាវបណ្ឌិត ពេជ ចន្ទមុន្នី ហ៊ុន ម៉ាណែត** អនុប្រធានអចិន្ត្រៃយ៍កាកបាទក្រហមកម្ពុជា នៅមណ្ឌលសន្និបាត និងពិព័រណ៍អន្តរជាតិជ្រោយចង្វារ រាជធានីភ្នំពេញ។
- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីផ្សេងៗ ចំនួន ៤លើក ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា រួមមាន៖ ពិធីអបអរសាទរខួប២០ឆ្នាំ នៃកម្ពុជា ចូលជាសមាជិកអង្គការពាណិជ្ជកម្មពិភពលោក (WTO), ពិធីបើកការដ្ឋានសាងសង់អគារមជ្ឈមណ្ឌលកណ្តាល អគារចំណត រោងជាង និងអគារវេជ្ជសាស្ត្រស៊ីក្លូត្រុង នៃមន្ទីរពេទ្យកាល់ម៉ែត, ពិធីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៣០ឆ្នាំ ថ្ងៃបង្កើតកងពលតូចលេខ៧០ ( ១៥ តុលា ១៩៩៤- ១៥ តុលា ២០២៤ ) និងពិធីបិទការប្រកួតកីឡាយុទ្ធគុនចម្រុះខ្មែរបុរាណ នៅរាជធានីភ្នំពេញ។
- អញ្ជើញជូន និងទទួលដំណើរ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រ នៃបុរីក្សត្រលុចសំបួ នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។
- អញ្ជើញជូន និងទទួលដំណើរ **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ ( IPU-149$^{th}$ ) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស នៅអាកាសយានដ្ឋានអន្តរជាតិភ្នំពេញ។

- អញ្ជើញចូលរួមវេទិកាកិច្ចប្រជុំពិគ្រោះយោបល់ជាមួយថ្នាក់ដឹកនាំក្រុង ស្រុក ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន និងនាយប៉ុស្តិ៍នគរបាលរដ្ឋបាល នៅស្រុកព្រះស្តេច និងស្រុកកំពង់ត្របែក ខេត្តព្រៃវែង ស្រុកស្វាយជ្រុំ និងក្រុងស្វាយរៀង ខេត្តស្វាយរៀង និង
- អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មកម្មសិក្សាអាស៊ី របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ នៅស្រុកកំចាយមារ ខេត្តព្រៃវែង។

❖ ដោយឡែកសមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខ ប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ ក្រុមគ្រូពេទ្យ អតីតមន្ត្រីរាជការជានិវត្តជន អតីតយុទ្ធជន យុវជន យុវនារី ក្រុមប្រឹក្សាឃុំ សង្កាត់ ស្មៀន នាយប៉ុស្តិ៍នគរបាលរដ្ឋបាល និងអាជ្ញាធរគ្រប់លំដាប់ថ្នាក់ ដើម្បីពង្រឹងតួនាទី ភារកិច្ចរបស់ក្រុមប្រឹក្សាឃុំ សង្កាត់នៅមូលដ្ឋាន ស្វែងយល់អំពីវឌ្ឍនភាពការងារ ការងារសន្តិសុខ សណ្តាប់ធ្នាប់ ការអភិវឌ្ឍមូលដ្ឋាន ការផ្តល់សេវាសាធារណៈជូនប្រជាពលរដ្ឋ និងការអនុវត្តគោលនយោបាយនានា ពិនិត្យហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ ដោះស្រាយទុក្ខលំបាករបស់ប្រជាពលរដ្ឋ និងបញ្ហាប្រឈមនានា នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា ចំនួន ៨០លើក ព្រមទាំងបានអញ្ជើញជាកិត្តិយសក្នុងពិធីសម្ពោធសមិទ្ធផលនានា និងពិធីផ្លូវការផ្សេងៗ ចំនួន ១៥៦លើក។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញប្រគល់ខោអាវកីឡាបាល់ទាត់ ដែលជាអំណោយរបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ជូនក្រុមបាល់ទាត់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភាវ័យចំណាស់ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងគណៈប្រតិភូ អញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** អញ្ជើញគោរពវិញ្ញាណក្ខន្ធសព **ឯកឧត្តម ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិ នៃកម្ពុជា នៅគេហដ្ឋាននៃសព ស្ថិតក្នុងសង្កាត់ជ្រោយចង្វារ ខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។

❖ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា **ឯកឧត្តម ខេង សិទ្ធិគុណ ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា និងគណៈប្រតិភូ បានអញ្ជើញគោរពវិញ្ញាណក្ខន្ធសព**ឧបាសិកា ប៊ួយ ហ៊ាន** ត្រូវជាម្តាយបង្កើត **លោក អ៊ី ឆក៏រុណ** ប្រធាននាយកដ្ឋានគ្រប់គ្រងអគារ សារពើភណ្ឌ និងសំណង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅគេហដ្ឋាននៃសព ស្ថិតក្នុងខណ្ឌសែនសុខ រាជធានីភ្នំពេញ។

- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា និង**ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** អញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា ថ្វាយកម្រងផ្កាគោរពព្រះវិញ្ញាណក្ខន្ធ **ព្រះករុណាព្រះបាទសម្តេចព្រះ នរោត្តម សីហនុ ព្រះមហាវីរក្សត្រ ព្រះវររាជបិតាឯករាជ្យ បូរណភាពទឹកដី និងឯកភាពជាតិខ្មែរ " ព្រះបរមរតនកោដ្ឋ "** គម្រប់ខួប១២ឆ្នាំ នៅមណ្ឌបតម្កល់ព្រះបរមរូប សួនច្បារខាងកើតវិមានឯករាជ្យ រាជធានីភ្នំពេញ។
- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** និងសមាជិកព្រឹទ្ធសភា អញ្ជើញចូលរួមគោរពវិញ្ញាណក្ខន្ធ និងពិធីបូជាសព **ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម។
- ❖ **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានៈ
  - ▪ អញ្ជើញចូលរួមកិច្ចប្រជុំពិនិត្យវឌ្ឍនភាពការងារ និងពិភាក្សាភារកិច្ចត្រូវត្រៀមលក្ខណៈរៀបចំព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៤ នៅសាលប្រជុំអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិរៀបចំបុណ្យជាតិ និងអន្តរជាតិ។
  - ▪ អញ្ជើញអមដំណើរ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** អញ្ជើញគោរពវិញ្ញាណក្ខន្ធសព**ឧបាសិកា ប៊ួយ ហ៊ាន** ត្រូវជាម្តាយបង្កើតរបស់ **លោក អ៊ី ធុគីរុណា** ប្រធាននាយកដ្ឋានគ្រប់គ្រងអគារ សារពើភណ្ឌ និងសំណង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុនៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា និង
  - ▪ អញ្ជើញចូលរួមកិច្ចប្រជុំ និងពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ចំនួន ៩លើក។
- ❖ **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បានៈ
  - ▪ អញ្ជើញជាតំណាងដ៏ខ្ពង់ខ្ពស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា អញ្ជើញដឹកនាំក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌កម្ពុជា( AMH ) របស់សាធារណរដ្ឋបារាំង ចុះពិនិត្យ និងព្យាបាលជំងឺទូទៅ ជូនប្រជាពលរដ្ឋ ដោយឥតគិតថ្លៃ នៅខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។ ហើយក្នុងឱកាសនោះផងដែរ **ឯកឧត្តម** ក៏បានប្រគល់នូវរទេះរុញ ចំនួន ១គ្រឿង ដែលជាអំណោយរបស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា ជូនប្រជាពលរដ្ឋម្នាក់ដែលពិការដោយសារជំងឺលើសឈាម និង
  - ▪ អញ្ជើញចូលរួមពិធីផ្សេងៗ នៅរាជធានីភ្នំពេញ ចំនួន ៦លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតថ្វាយព្រះពរ និងជូនពររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាទូលថ្វាយ និងគោរពជូន៖
  - **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាស នៃព្រះរាជពិធីគម្រប់ខួប២០ព្រះវស្សា នៃការគ្រងព្រះបរមសិរីរាជសម្បត្តិរបស់ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង
  - **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា ក្នុងឱកាសនៃពិធីចម្រើនជន្មាយុគម្រប់ ៤៧ឆ្នាំ ឈានចូល ៤៨ឆ្នាំ។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភាគោរពជូន **ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ចម ប្រសិទ្ធ ឯកឧត្តមកិត្តិឧទ្ទេសបណ្ឌិត ប៉ុល សារឿន** និង **ឯកឧត្តម ខៀវ កាញារីទ្ធ** ក្នុងឱកាសដែលត្រូវបាន **ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា សព្វព្រះរាជហឫទ័យត្រាស់បង្គាប់តែងតាំងជា " **ឧត្តមប្រឹក្សាផ្ទាល់ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** "។
- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតរំលែកទុក្ខរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា គោរពជូន៖
  - **លោកជំទាវ កែវ ស្រីពេជ្រ** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមនាយឧត្តមសេនីយ៍ សែម សុវណ្ណនី** អនុប្រធានទី១ គណៈកម្មាធិការជាតិសម្របសម្រួលកិច្ចការបញ្ជូនកងកម្លាំងចូលរួមបេសកកម្មរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ អនុប្រធានទី២ អាជ្ញាធរកម្ពុជាគ្រប់គ្រងសកម្មភាពមីន និងជាអគ្គនាយកមជ្ឈមណ្ឌលជាតិគ្រប់គ្រងកងកម្លាំងរក្សាសន្តិភាព បោសសម្អាតមីន និងកាកសំណល់សង្គ្រាម។
  - **លោកជំទាវ ខៀវ ស៊ីណា** ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់ **ឯកឧត្តមបណ្ឌិត ជា ចាន់តូ** តំណាងរាស្ត្រមណ្ឌលខេត្តកំពង់ធំ និងជាអគ្គទេសាភិបាលកិត្តិយសធនាគារជាតិនៃកម្ពុជា។
  - **លោក អ៊ី ឆភីរុណ** ប្រធាននាយកដ្ឋានគ្រប់គ្រងអគារ សារពើភណ្ឌ និងសំណង់ នៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់**ឧបាសិកា ប៊ួយ ហ៊ាន** និង
  - **លោកស្រី យី លីវណ្ណ** អនុប្រធានការិយាល័យជំនួយការគណៈកម្មការទី៨ព្រឹទ្ធសភា ព្រមទាំងក្រុមគ្រួសារ ចំពោះមរណភាពរបស់**ឧបាសក ឆៃ យន់លី**។
- បានរៀបចំពិធីសំណេះសំណាល និងពិសាអាហារសាមគ្គីជាមួយនិវត្តជននិងមន្ត្រីរាជការវ័យចំណាស់នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក្នុងឱកាសទិវាមនុស្សចាស់កម្ពុជា និងទិវាមនុស្សចាស់អន្តរជាតិលើកទី២៦ (១ តុលា ឆ្នាំ២០២៤) ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា នៅភោជនីយដ្ឋានទន្លេបាសាក់២ រាជធានីភ្នំពេញ។

- បានធ្វើបទបង្ហាញស្តីពី " រចនាសម្ព័ន្ធ តួនាទី និងភារកិច្ចរបស់ព្រឹទ្ធសភា " ប្រគេនព្រះសង្ឃ និងជូនសាស្ត្រាចារ្យ និងនិស្សិត នៃសាកលវិទ្យាល័យគ្រប់គ្រង និងសេដ្ឋកិច្ច (UME) ខេត្តបាត់ដំបង និង
- បានទទួលពាក្យបណ្តឹងចូល ចំនួន ២បណ្តឹង កំពុងពិនិត្យសិក្សា ចំនួន ៦បណ្តឹង ផ្តល់ព័ត៌មានទៅម្ចាស់បណ្តឹង ចំនួន ៨បណ្តឹង តម្កល់ទុកមិនចាត់ការ ចំនួន ៣បណ្តឹង ធ្វើកំណត់បង្ហាញពាក្យបណ្តឹង ចំនួន ៨បណ្តឹង ទទួលលិខិតឆ្លើយតបពីការដោះស្រាយពីស្ថាប័នពាក់ព័ន្ធ ចំនួន ១បណ្តឹង។

## ៣-មុខងារសហប្រតិបត្តិការអន្តរជាតិ

- បានរៀបចំចាត់ចែង និងផ្តល់សេវាជូនប្រមុខរដ្ឋស្តីទី នៃព្រះរាជាណាចក្រកម្ពុជា ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា៖

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រមុខរដ្ឋស្តីទី** នៃព្រះរាជាណាចក្រកម្ពុជា បានអនុញ្ញាតឱ្យ **ឯកឧត្តម ចាង យ៉ុនហ្គុន** (Jang Yun Gon) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតកូរ៉េ ប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា។

❖ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** បានអនុញ្ញាតឱ្យឥស្សរជនជាន់ខ្ពស់ និងគណៈប្រតិភូអន្តរជាតិនានា ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅវិមានព្រឹទ្ធសភា ចំនួន ១លើក និងវិមាន៧មករា ចំនួន ៣លើក រួមមាន៖

- **ឯកឧត្តម កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា** (Katsuhiro Shinohara) ប្រធានតំណាងមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា នៅវិមានព្រឹទ្ធសភា។
- **ឯកឧត្តម គ្រីស្យង់ ឡឺសែវី** (Christian Lechervy) ឯកអគ្គរដ្ឋទូត និងជាប្រេសិតពិសេសបារាំង សម្រាប់សាធារណរដ្ឋសហភាពមីយ៉ាន់ម៉ា នៅវិមាន៧មករា។
- **ឯកឧត្តម ឈី ឈីងសាន** (QU Qingshan) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្របក្ស និងអក្សរសាស្ត្រ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នៅវិមាន៧មករា និង
- **ឯកឧត្តម ស៊ិនឡាវ៉ង់ ឃុតផៃធូន** (Sinlavong Khoutphaythoune) ប្រធានរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ នៅវិមាន៧មករា។

❖ ឯកឧត្តម **ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** បានអញ្ជើញដឹកនាំគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រ នៃបុរីក្សត្រលុចសំបួ។ ហើយក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុប្រធានទី១ព្រឹទ្ធសភា** បានអញ្ជើញជួបពិភាក្សាការងារ និងចូលរួមពិធីពិសាអាហារការងារ ចំនួន ១២លើក រួមមាន៖

- អញ្ជើញជួបពិភាក្សាការងារជាមួយគណៈប្រតិភូអន្តរជាតិនានា ចំនួន ៨លើក រួមមាន៖
  - **ឯកឧត្តម** Hilarion ETONG ប្រធាន APF នៅទីស្នាក់ការសភាប្រើភាសាបារាំង។

- **ឯកឧត្តម** André REICHARDT អនុប្រធានក្រុមសភាជាតិបារាំង នៃសភាប្រើភាសាបារាំង សមាជិកក្រុមស្រាវជ្រាវហ្វ្រង់កូហ្វូនី អនុប្រធានគណៈកម្មការកិច្ចការអឺរ៉ុប និងជាលេខាគណៈកម្មការច្បាប់រដ្ឋធម្មនុញ្ញ នីតិកម្ម ការបោះឆ្នោត បទបញ្ជាផ្ទៃក្នុង និងរដ្ឋបាលទូទៅ នៃព្រឹទ្ធសភាបារាំង។
- **លោក** Christophe-André FRASSA អនុប្រធានគណៈកម្មការច្បាប់រដ្ឋធម្មនុញ្ញ នីតិកម្ម ការបោះឆ្នោត បទបញ្ជាផ្ទៃក្នុង និងរដ្ឋបាលទូទៅ នៃព្រឹទ្ធសភាបារាំង ។
- **ឯកឧត្តម** Marc THEWES ប្រធានក្រុមប្រឹក្សារដ្ឋ នៃបុរីក្សត្រលុចសំបួ នៅព្រឹទ្ធសភាបុរីក្សត្រលុចសំបួ។
- **លោកស្រី** Edith STEIN ទីប្រឹក្សាជាន់ខ្ពស់ទទួលបន្ទុកកិច្ចការអន្តរជាតិ មជ្ឈិមបូព៌ា អាស៊ីអាគ្នេយ៍ នៃសភាពាណិជ្ជកម្ម នៃបុរីក្សត្រលុចសំបួ នៅព្រឹទ្ធសភាបុរីក្សត្រលុចសំបួ។
- **លោក** Fabrice ROBERT អគ្គនាយកទទួលបន្ទុកនីតិកម្ម និងត្រួតពិនិត្យរបស់ព្រឹទ្ធសភា នៃបុរីក្សត្រលុចសំបួ។
- **លោក** Philippe DELIVET ប្រធាននាយកដ្ឋានទំនាក់ទំនងអន្តរជាតិ និងពិធីការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាបារាំង នៅព្រឹទ្ធសភាបារាំង និង
- **លោកស្រី** Marion JOLIVET ប្រធាននាយកដ្ឋានសម័យប្រជុំពេញអង្គ នៅព្រឹទ្ធសភាបារាំង។

▪ អញ្ជើញចូលរួមពិធីពិសាអាហារការងារពេលថ្ងៃត្រង់ និងពេលល្ងាចជាមួយគណៈប្រតិភូអន្តរជាតិនានា ចំនួន ៤លើក រួមមាន៖

- **ឯកឧត្តម** Loïc HERVÉ អនុប្រធានព្រឹទ្ធសភាបារាំង ទទួលបន្ទុកកិច្ចសហប្រតិបត្តិការអន្តរសភា និងក្រុមអន្តរសភាមិត្តភាព។
- **លោក** Éric TAVERNIER អគ្គលេខាធិការព្រឹទ្ធសភាបារាំង។
- **លោក** Vincent ÉBLÉ ប្រធានក្រុមអន្តរសភាមិត្តភាពបារាំង-កម្ពុជា និង
- **ឯកឧត្តម** Michel WOLTER អនុប្រធានព្រឹទ្ធសភា នៃបុរីក្សត្រលុចសំបួ។

❖ **ឯកឧត្តម ង្វៀន សុខុន អនុប្រធានទី១ព្រឹទ្ធសភា បាន៖**

▪ អញ្ជើញអមសម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា អនុញ្ញាតឱ្យឯកឧត្តម **ស៊ិនឡាវង់ ឃុតផៃធូន** (Sinlavong Khoutphaythoune) ប្រធានរណសិរ្សអភិវឌ្ឍន៍ជាតិឡាវ ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារនៅវិមាន៧មករា។

▪ អនុញ្ញាតឱ្យ **ឯកឧត្តម ឈី ឈីងសាន** (QU Qingshan) សមាជិកគណៈកម្មាធិការមជ្ឈិមបក្ស និងជាប្រធានវិទ្យាស្ថានប្រវត្តិសាស្ត្របក្ស និងអក្សរសាស្ត្រ នៃគណៈកម្មាធិការមជ្ឈិមបក្សកុម្មុយនីស្តចិន នៅវិមាន៧មករា។

- អញ្ជើញចូលរួមក្នុងកម្មវិធី Cocktail Reception រៀបចំឡើងដោយស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា សហការជាមួយមជ្ឈមណ្ឌលខ្មែរសិក្សាកិច្ចការតំបន់ (CCRS) នៅសណ្ឋាគារ Fairfield by Marriot និង
- អញ្ជើញចូលរួមពិសាអាហារការងារពេលថ្ងៃត្រង់ នៅនិវេសនដ្ឋានស្ថានទូតបារាំង ប្រចាំព្រះរាជាណាចក្រកម្ពុជា។

❖ **ឯកឧត្តម អ៊ុច បូររិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា** បានដឹកនាំគណៈប្រតិភូជាន់ខ្ពស់ នៃសភាកម្ពុជា អញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ (IPU-149th) និងកិច្ចប្រជុំពាក់ព័ន្ធ ក្រោមមូលបទ " ការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា នវានុវត្តន៍ សម្រាប់អនាគតប្រកបដោយសន្តិភាព និងចីរភាពកាន់តែប្រសើរ " នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដោយមានការអញ្ជើញចូលរួមពីសមាជិកសភាជុំវិញពិភពលោកប្រមាណ ចំនួន ៦៣០រូប នៃ ១៣០ប្រទេស ហើយក្នុងឱកាសនោះផងដែរ **ឯកឧត្តមអនុប្រធានទី២ព្រឹទ្ធសភា** បានអញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយភាគីបរទេស និងចូលរួមក្នុងពិធីផ្សេងៗ ចំនួន ៥លើក រួមមាន៖

- អញ្ជើញជួបពិភាក្សាការងារទ្វេភាគីជាមួយភាគីបរទេស ចំនួន ៤លើក រួមមាន៖
  - **ឯកឧត្តម អ៊ីនយ៉ុង លី** (In-Young LEE) ប្រធានគណៈប្រតិភូសភា នៃសាធារណរដ្ឋកូរ៉េ។
  - **ឯកឧត្តម ធៀន ស៊ឺជុន** (Tian Xuejun) ប្រធានគណៈប្រតិភូ នៃសភាចិន។
  - **ឯកឧត្តម យុឈិអ៊ិ អាគីរ៉ា** (YOSHII Akira) ប្រធានគណៈប្រតិភូនៃព្រឹទ្ធសភាជប៉ុន និង
  - **លោកជំទាវបណ្ឌិត ទូលៀ អេកសិន** (Dr. Tulia Arkson) ប្រធានសហភាពអន្តរសភា (IPU) និងជាប្រធានសភាតង់ហ្សានៀ។
- អញ្ជើញថ្លែងសុន្ទរកថា ក្រោមប្រធានបទ " **ការប្រើប្រាស់វិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ សម្រាប់អនាគតប្រកបដោយសន្តិភាព និងចីរភាពកាន់តែប្រសើរ** "។

❖ **ឯកឧត្តម ងី ច័ន្ទ្រផល** ប្រធានគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមមហាសន្និបាតសហភាពអន្តរសភាលើកទី១៤៩ (IPU-149th) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។

❖ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានគណៈកម្មការទី២ព្រឹទ្ធសភា បានដឹកនាំគណៈប្រតិភូ អញ្ជើញចូលរួមកិច្ចប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ស្តីពី " កិច្ចការសង្គម និងវប្បធម៌ នៃសភាតំបន់អាស៊ី (APA)" នៅទីក្រុងម៉ូស្គូ សហព័ន្ធរុស្ស៊ី។

❖ **ឯកឧត្តមបណ្ឌិត ម៉ុង ឫទ្ធី** ប្រធានគណៈកម្មការទី៣ព្រឹទ្ធសភា បានអញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីអបអរសាទរទិវាបុណ្យជាតិ នៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។

- **ព្រះអង្គម្ចាស់ ស៊ីសុវត្ថិ ធម្មិកោ** សមាជិកគណៈកម្មការទី៣ព្រឹទ្ធសភា បានយាងចូលរួមពិធីបុណ្យថ្ងៃនៃការរួបរួម នៃសាធារណរដ្ឋសហព័ន្ធអាល្លឺម៉ង់ នៅលើនាវាទេសចរណ៍ ស្ថិតក្នុងខណ្ឌជ្រោយចង្វារ រាជធានីភ្នំពេញ។
- **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានគណៈកម្មការទី៥ព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមសន្និសីទអន្តរជាតិស្តីពី ការបំលាស់ទីរបស់ប្រជាពលរដ្ឋ នៅក្នុងប្រទេសហ្វ្រង់កូហ្វូន (La mobilité citoyenne francophone pour la création, l'innovation et l'entrepreneuriat) រៀបចំដោយសភាប្រើភាសាបារាំង (APF) សហការជាមួយទីភ្នាក់ងារបារាំងសម្រាប់អភិវឌ្ឍន៍(AFD) ដើម្បីប្រមូលយោបល់ និងអនុសាសន៍ជូនប្រមុខរដ្ឋ ប្រមុខរដ្ឋាភិបាល ដែលចូលរួមកិច្ចប្រជុំកំពូលអង្គការអន្តរជាតិប្រើភាសាបារាំងលើកទី១៩ នៅក្រុមប្រឹក្សាសេដ្ឋកិច្ចសង្គម ទីក្រុងប៉ារីស នៃសាធារណរដ្ឋបារាំង។
  - អញ្ជើញចូលរួមកិច្ចប្រជុំអំពីវឌ្ឍនភាពការងារជាមួយអនុគណៈកម្មការរៀបចំមហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP-12th) និងកិច្ចប្រជុំពាក់ព័ន្ធ ដើម្បីត្រៀមរៀបចំមហាសន្និបាតសន្និសីទអន្តរជាតិ នៃបណ្តាគណបក្សនយោបាយនៅអាស៊ី លើកទី១២ (ICAPP-12th) ដែលមានសមាសភាពចូលរួម ចំនួន៧០នាក់ នៅវិមានព្រឹទ្ធសភា។
  - អញ្ជើញជួបពិភាក្សាការងារជាមួយ **លោក Andrew McDowell** អគ្គនាយក នៃធនាគារវិនិយោគអឺរ៉ុប ដែលមានទីតាំងនៅបុរីក្សេត្រលុចសំបួ។
  - អញ្ជើញដឹកនាំសមាជិក សមាជិកាគណៈប្រតិភូព្រឹទ្ធសភាកម្ពុជា អញ្ជើញពិសាអាហារការងារពេលល្ងាច តាមការអញ្ជើញរបស់ **ឯកឧត្តម Gusty Graas** តំណាងរាស្ត្រ និងជាប្រធានគណៈកម្មការកិច្ចការបរទេស អឺរ៉ុប កិច្ចសហប្រតិបត្តិការ អន្តោប្រវេសន៍ និង Grande Région នៃសភាតំណាងរាស្ត្រ នៃបុរីក្សេត្រលុចសំបួ ដោយមានការអញ្ជើញចូលរួមផងដែរពីសមាជិក សមាជិកា នៃគណៈកម្មការកិច្ចការបរទេសមួយចំនួនទៀតតំណាងឱ្យគណបក្សខុសៗគ្នា នៃសភាតំណាងរាស្ត្រ នៃបុរីក្សេត្រលុចសំបួ។
  - អញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំជាមួយ **ឯកឧត្តម សួស យ៉ារ៉ា** ប្រធានគណៈកម្មការទី៥រដ្ឋសភា ដើម្បីពិភាក្សាការងារអំពីការរៀបចំកិច្ចប្រជុំអន្តរសភាអាស៊ាន (ASEAN Inter-Parliamentary Assembly- AIPA) នៅទីក្រុងវៀងច័ន្ទន៍ ប្រទេសឡាវ នៅវិមានព្រឹទ្ធសភា។
  - អញ្ជើញចូលរួមកិច្ចប្រជុំត្រៀមលក្ខណៈចូលរួមមហាសន្និបាតអន្តរសភាអាស៊ាន លើកទី៤៥ (45th AIPA General Assembly) ដែលនឹងប្រព្រឹត្តទៅនៅសាធារណរដ្ឋប្រជាធិបតេយ្យប្រជាមានិតឡាវ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់ **សម្តេចមហារដ្ឋសភាធិការធិបតី ឃួន សុដារី** ប្រធានរដ្ឋសភា នៃព្រះរាជាណាចក្រកម្ពុជា នៅវិមានរដ្ឋសភា។

- អញ្ជើញចូលរួមជាកិត្តិយសក្នុងពិធីលៀងសាយភោជន៍ រៀបចំដោយ **ឯកឧត្តម ផាក ជុងវុក** (Park Jung-Wook) ឯកអគ្គរដ្ឋទូតវិសាមញ្ញ និងពេញសមត្ថភាព នៃសាធារណរដ្ឋកូរ៉េ និង**លោកជំទាវ** ដើម្បីអបអរសាទរទិវាបុណ្យជាតិ នៃសាធារណរដ្ឋកូរ៉េ នៅសណ្ឋាគារសូហ្វីតែលភ្នំពេញភូគីត្រា។
- អញ្ជើញទទួលជួប **លោក Ivan KABACOFF** អ្នករៀបចំកម្មវិធីតុមូលស្តីពី ភាពរំកិលនៃអនាគតៈ ចរាចរក្នុងកន្លែងនិយាយភាសាបារាំងរបស់សិស្ស បុគ្គលហាត់ការកូនជាង និងបុគ្គលស្ម័គ្រចិត្តវ័យក្មេង នៅក្នុងសន្និសីទរៀបចំដោយសភាប្រើភាសាបារាំង (APF) តាមប្រព័ន្ធនិម្មិត នៅរាជធានីភ្នំពេញ។

❖ **ឯកឧត្តមបណ្ឌិត ចែម វីឡា** ប្រធានក្រុម **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធាន **លោកជំទាវ មុំ សណ្ដាប់** សមាជិកា និង**ឯកឧត្តម សត ណាឌី** សមាជិក នៃក្រុមមិត្តភាពព្រឹទ្ធសភា នៃព្រះរាជាណាចក្រកម្ពុជា ជាមួយក្រុមប្រឹក្សាសហព័ន្ធ នៃសភាសហព័ន្ធ នៃសហព័ន្ធរុស្ស៊ី បានទទួលជួបពិភាក្សាការងារជាមួយ**ឯកឧត្តម** Anatoly Borovik ឯកអគ្គរដ្ឋទូតសហព័ន្ធរុស្ស៊ី ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅបន្ទប់ប្រជុំគណៈកម្មការទី៥ព្រឹទ្ធសភា អគារE ជាន់ទី១។

❖ **លោកជំទាវបណ្ឌិត ចាន់ សុទ្ធាវី** ប្រធានគណៈកម្មការទី៦ព្រឹទ្ធសភា និងជាអនុប្រធានក្រុមអន្តរសភា អាស៊ាន(AIPA) **ឯកឧត្តម អាយ ខន** អនុប្រធានគណៈកម្មការ និងជាសមាជិកក្រុមអន្តរសភាអាស៊ាន(AIPA) បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំដើម្បីត្រៀមលក្ខណៈចូលរួមកិច្ចប្រជុំរវាងថ្នាក់ដឹកនាំអាយប៉ា លើកទី៤៥ (AIPA-45th) ជាមួយប្រមុខដឹកនាំអាស៊ានក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់របស់**ឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត ជាម យៀប អនុប្រធានទី១ រដ្ឋសភា** និងជាប្រធានក្រុមរដ្ឋសភាកម្ពុជា នៃស្ថាប័នអន្តរសភា នៃអន្តរសភាអាស៊ាន។

❖ **ឯកឧត្តម ម៉ាន់ ឈឿន** អនុប្រធានគណៈកម្មការទី៧ព្រឹទ្ធសភា និង**លោកជំទាវ មុំ សណ្ដាប់** សមាជិកាគណៈកម្មការទី៦ព្រឹទ្ធសភា បានអញ្ជើញអមដំណើរគណៈប្រតិភូព្រឹទ្ធសភាកម្ពុជាទៅបំពេញទស្សនកិច្ចការងារនៅព្រឹទ្ធសភា នៃសាធារណរដ្ឋបារាំង និងសភាតំណាងរាស្ត្រលុចសំបួ ដើម្បីបន្តពង្រឹងកិច្ចសហប្រតិបត្តិការ និងលើកកម្ពស់ការងារការទូតសភា ដែលស្របទៅតាមចក្ខុវិស័យរបស់ព្រឹទ្ធសភា នីតិកាលទី៥ ក្រោមការដឹកនាំដ៏ខ្ពង់ខ្ពស់របស់ **ឯកឧត្តម ប្រាក់ សុខុន អនុប្រធានទី១ព្រឹទ្ធសភា** និងជាប្រធានក្រុមមិត្តភាពកម្ពុជា-បារាំង ហើយជាអនុប្រធានសភាប្រើភាសាបារាំង និងជាប្រធានគណៈប្រតិភូ។

❖ **ឯកឧត្តម អ៊ុំ សារឹទ្ធ** ប្រធានគណៈកម្មការទី៩ព្រឹទ្ធសភា បានអនុញ្ញាតឱ្យ**លោក ណាកាសិ កិនស៊ូកិ** (Nagase Kensuke) អគ្គទីប្រឹក្សាស្ថានទូតជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា ជួបសវនាការការងារ នៅបន្ទប់ឯកឧត្តមប្រធាន អគារF ព្រឹទ្ធសភា។

❖ **ឯកឧត្តមបណ្ឌិត ធន់ វឌ្ឍនា** ប្រធានក្រុម **ឯកឧត្តម ខៀវ មុត** អនុប្រធាន **ឯកឧត្តម អ៊ុក គង់** សមាជិក និង**ឯកឧត្តម ឡាន់ ឆន** សមាជិក នៃក្រុមមិត្តភាពព្រឹទ្ធសភាកម្ពុជា-ជប៉ុន បានអញ្ជើញជួបពិភាក្សាការងារ និងពិសាអាហារថ្ងៃត្រង់ជាមួយ **ឯកឧត្តម អ៊ូអិណុ អាត់ស៊ូស៊ី** (Ueno

Atsushi ) ឯកអគ្គរាជទូតវិសាមញ្ញ និងពេញសមត្ថភាព នៃព្រះរាជាណាចក្រជប៉ុន ប្រចាំព្រះរាជាណាចក្រកម្ពុជា នៅស្ថានទូតជប៉ុន រាជធានីភ្នំពេញ។

- **ឯកឧត្តម គង់ មុនីកា** សមាជិកគណៈកម្មការទី១ព្រឹទ្ធសភា បានអញ្ជើញចូលរួមកម្មវិធី International Visitor Leadership Program ( IVLP ) ក្រោមប្រធានបទ " Not Too Young to Run " នៅសហរដ្ឋអាមេរិក។

- **ឯកឧត្តម សុក ហាច** សមាជិកគណៈកម្មការទី៧ព្រឹទ្ធសភា បានអញ្ជើញចូលរួមពិធីប្រារព្ធខួបទិវាឯកភាពជាតិអាល្លឺម៉ង់ លើកទី៣៤ នៅនិវេសនដ្ឋានឯកអគ្គរដ្ឋទូតអាល្លឺម៉ង់ រាជធានីភ្នំពេញ។

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមអម **សម្តេចអគ្គមហាសេនាបតីតេជោ** ប្រធានព្រឹទ្ធសភា ក្នុងជំនួបពិភាក្សាការងារជាមួយឯកឧត្តម ចាង យ៉ុនហ្គុន ( Jang Yun Gon ) ឯកអគ្គរដ្ឋទូត នៃសាធារណរដ្ឋប្រជាមានិតប្រជាធិបតេយ្យកូរ៉េ និងឯកឧត្តម កាត់ស៊ូហ៊ីរ៉ូ ស៊ីណូហារ៉ា ( Katsuhiro Shinohara ) ប្រធានតំណាងមូលនិធិគាំទ្រការអប់រំអន្តរជាតិកម្ពុជា នៅវិមានព្រឹទ្ធសភា។
  - អញ្ជើញចូលរួមអម **ឯកឧត្តម អ៊ុច បូរិទ្ធ អនុប្រធានទី២ព្រឹទ្ធសភា** ដឹកនាំគណៈប្រតិភូជាន់ខ្ពស់ នៃសភាកម្ពុជា ចូលរួមមហាសន្និបាតសហភាពអន្តរសភា លើកទី១៤៩ ( IPU-149$^{th}$ ) និងកិច្ចប្រជុំពាក់ព័ន្ធ នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស។
  - អញ្ជើញចូលរួមកិច្ចប្រជុំសមាគមអគ្គលេខាធិការសភាក្នុងក្របខ័ណ្ឌ នៃសហភាពអន្តរសភា ( IPU ) នៅទីក្រុងហ្សឺណែវ ប្រទេសស្វីស ដែលមានការចូលរួមពីអគ្គលេខាធិការ នៃសភាដែលមកពីបណ្តាប្រទេសនានា ចំនួន ១០០។
  - អនុញ្ញាតឱ្យ **លោក យី ច័ន្ទប្រាស្នា** នាយកប្រតិបត្តិថ្មី នៃមជ្ឈមណ្ឌលសភាអាស៊ី ( PCAsia ) និងសហការី ចូលជួបសម្តែងការគួរសម និងពិភាក្សាការងារ នៅបន្ទប់ប្រជុំឯកឧត្តម អគ្គលេខាធិការព្រឹទ្ធសភា និង
  - ទទួលជួបពិភាក្សាការងារ និងផ្លាស់ប្តូរយោបល់ជាមួយ **ឯកឧត្តម ដូមីនិក វីលៀម** ( Dominic Williams ) ឯកអគ្គរាជទូតអង់គ្លេស ប្រចាំព្រះរាជាណាចក្រកម្ពុជា អំពីកិច្ចសហប្រតិបត្តិការនានា ដែលជាផលប្រយោជន៍រួម នៃស្ថាប័នទាំងពីរ នៅបន្ទប់ប្រជុំឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។

- **ឯកឧត្តម ខេង សិទ្ធិគុណា** អគ្គលេខាធិការស្តីទីព្រឹទ្ធសភា បានអញ្ជើញចូលរួមក្នុងជំនួបសម្តែងការគួរសម និងពិភាក្សាការងាររវាង**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** ជាមួយឥស្សរជនជាន់ខ្ពស់ និងគណៈប្រតិភូអន្តរជាតិនានា នៅវិមាន៧មករា ចំនួន ៣លើក។

- បានរៀបចំ និងចាត់ចែងបញ្ជូនសារលិខិតអបអរសាទររបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** គោរពជូន៖

- **ឯកឧត្តម ប្រាបូវ៉ូ ស៊ូប៊ីយ៉ាន់តូ** (Prabowo Subianto) ក្នុងឱកាសដែលឯកឧត្តមចូលកាន់តំណែងជាប្រធានាធិបតី នៃសាធារណរដ្ឋឥណ្ឌូណេស៊ី និង
- **ឯកឧត្តម លឿង គឿង** (Luong Cuong) ក្នុងឱកាសដែលឯកឧត្តមបានជាប់ឆ្នោតជាប្រធានរដ្ឋ នៃសាធារណរដ្ឋសង្គមនិយមវៀតណាម។

- បានចាត់ចែងបញ្ជូនសារលិខិតថ្លែងអំណរគុណរបស់ **ឯកឧត្តម វ៉ាង ហ៊ូនីង** ប្រធានគណៈកម្មាធិការជាតិសភាប្រឹក្សានយោបាយប្រជាជនចិន ជូនចំពោះ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន ប្រធានព្រឹទ្ធសភា** នៃព្រះរាជាណាចក្រកម្ពុជា ដែលបានបញ្ជូនសារលិខិតអបអរសាទរជូន **ឯកឧត្តម វ៉ាង ហ៊ូនីង** ក្នុងឱកាសខួបលើកទី៧៥ នៃការបង្កើតសាធារណរដ្ឋប្រជាមានិតចិន និង
- បានសហការ និងទាក់ទងជាមួយស្ថានទូតសិង្ហបុរី ស្ថានទូតចិន ស្ថានទូតម៉ាឡេស៊ី ស្ថានទូតព្រុយណេដារូសាឡាម ស្ថានទូតឥណ្ឌា ស្ថានទូតថៃ ស្ថានទូតវៀតណាម ដៃគូអភិវឌ្ឍន៍ក្រៅប្រទេស ទីស្តីការគណៈរដ្ឋមន្ត្រី អង្គការសេវាកម្មអ្នកជំនាញការជាន់ខ្ពស់អាល្លឺម៉ង់(SES) បណ្ឌិត្យសភាបច្ចេកវិទ្យាឌីជីថលកម្ពុជា (CADT) វិទ្យាស្ថានវិទ្យាសាស្ត្រ បច្ចេកវិទ្យា និងនវានុវត្តន៍ វិទ្យាស្ថានប្រសិទ្ធ វិទ្យាស្ថានសាន់ប៉ាយស៍ មជ្ឈមណ្ឌលស្រាវជ្រាវច្បាប់ចិន-អាស៊ាន(CALRC) ក្រុមហ៊ុនកូហា និងក្រសួង ស្ថាប័ននានា ដើម្បីសម្រួលដល់កិច្ចការអន្តរជាតិ និងស្នើសុំអាហារូបករណ៍វគ្គបណ្តុះបណ្តាល ជំនួយ ព្រមទាំងការរៀបចំពិធីផ្សេងៗ។

## ៤-មុខងារអភិវឌ្ឍន៍ស្ថាប័ន

### ៤.១-កិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា៖

- **ឯកឧត្តម ឡាយ សំកុល** អគ្គលេខាធិការព្រឹទ្ធសភា បានអញ្ជើញជាអធិបតីដឹកនាំកិច្ចប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែកញ្ញា និងទិសដៅការងារខែតុលា ឆ្នាំ២០២៤ នៅសាលខាងជើង នៃវិមានព្រឹទ្ធសភា។
- **ឯកឧត្តម ខេង សិទ្ធិគុណ** អគ្គលេខាធិការរងព្រឹទ្ធសភា បានអញ្ជើញចូលរួមប្រជុំការងារសំខាន់ៗ ដឹកនាំដោយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា។
- **ឯកឧត្តម ឡោក ឆាយ** អគ្គលេខាធិការរងព្រឹទ្ធសភា បាន៖
  - អញ្ជើញចូលរួមប្រជុំការងារសំខាន់ៗ ដឹកនាំដោយឯកឧត្តមអគ្គលេខាធិការព្រឹទ្ធសភា និង
  - អញ្ជើញដឹកនាំប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គនាយកដ្ឋានសេវាច្បាប់ និងសមូហភាពដែនដី និងអគ្គនាយកដ្ឋានស្រាវជ្រាវ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា និងទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៤ នៅសាលពិសេសជាន់ក្រោម នៃវិមានព្រឹទ្ធសភា។

### ៤.២-ការងាររដ្ឋបាល និងហិរញ្ញវត្ថុ៖

- បានរៀបចំឧបសម្ព័ន្ធ នៃរបាយការណ៍អនុវត្តចំណូល-ចំណាយថវិកាជាតិរបស់ព្រឹទ្ធសភា រយៈពេល៦ខែ ចាប់ពីខែមេសា ដល់ខែកញ្ញា ឆ្នាំ២០២៤ នីតិកាលទី៥។

- បានបើកប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារបន្ថែម ប្រាក់ឧបត្ថម្ភពិនិត្យ និងព្យាបាលជំងឺ ប្រាក់ឧបត្ថម្ភធ្វើដំណើរ និងសេវាទំនាក់ទំនងប្រចាំខែតុលា ឆ្នាំ២០២៤ និងប្រាក់ឧបត្ថម្ភផ្សេងៗ ជូនសមាជិកព្រឹទ្ធសភា និងថ្នាក់ដឹកនាំ មន្ត្រីរាជការ បុគ្គលិកជាប់កិច្ចសន្យា ភ្នាក់ងារសន្តិសុខ ជំនួយការផ្ទាល់ អ្នកបើកបររថយន្ត និងនិវត្តជន នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមរយៈប្រព័ន្ធធនាគារ។
- បានបោះផ្សាយអាណត្តិ ផ្ញើទៅក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ រួមមាន៖
    - ថ្លៃប្រើប្រាស់អគ្គិសនី ចាប់ពីខែកុម្ភៈ ដល់ខែឧសភា ឆ្នាំ២០២៤។
    - ស្នើសុំទូទាត់បុរេប្រទានថវិកាទិញរថយន្ត Ford Everest Titanium ឆ្នាំ២០២៤ ចំនួន ១១គ្រឿង និងរថយន្ត Toyota Landcruiser 3.5VXR ឆ្នាំ២០២៤ ចំនួន ២គ្រឿង។
    - ស្នើសុំទូទាត់បុរេប្រទានថវិកា សម្រាប់ចំណាយបេសកកម្មជូនគណៈប្រតិភូជាន់ខ្ពស់ នៃព្រះរាជាណាចក្រកម្ពុជា ចំនួន ៧រូប អញ្ជើញចូលរួមមហាសន្និបាតលើកទី១៤៩ នៃសភាប្រើភាសាបារាំង (APF) និងកិច្ចប្រជុំពាក់ព័ន្ធ នៅប្រទេសកាណាដា និង
    - ស្នើសុំចំណាយពន្ធ និងអាករលតាបត្រ ប្រចាំឆ្នាំ២០២៤។
- បានធ្វើលិខិតស្នើសុំឥណទានបន្ថែមប្រាក់ឧបត្ថម្ភផ្សេងៗ ប្រចាំខែរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ខុទ្ទកាល័យប្រធាន-អនុប្រធានព្រឹទ្ធសភា (គិតចាប់ពីខែកញ្ញា ដល់ខែធ្នូ ឆ្នាំ២០២៤)។
- បានបង្វែរប្រាក់វិភាគទានជូនអង្គភាពបេឡាជាតិសន្តិសុខសង្គម (ប.ស.ស) របស់ថ្នាក់ដឹកនាំ មន្ត្រីរាជការ និងបុគ្គលិកជាប់កិច្ចសន្យា នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៤។
- បានផ្តល់សេវាថវិកាជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៥៤សំណើ ព្រមទាំងបានទូទាត់ការចំណាយផ្សេងៗ ចំនួន ៧៣សំណើ។
- បានដោះស្រាយសំណើផ្សេងៗ និងផ្គត់ផ្គង់វត្ថុអនុស្សាវរីយ៍ គ្រឿងបរិក្ខារ សម្ភារអនាម័យ សម្ភារការិយាល័យ ភេសជ្ជៈ និងអាហារសម្រន់សម្រាប់បម្រើដល់កិច្ចប្រជុំ សិក្ខាសាលា កម្មវិធីផ្សេងៗ និងជូនគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៤១សំណើ។
- បានថតចម្លងឯកសារ ចំនួន ១,៧៩៤ច្បាប់ អស់ក្រដាស ចំនួន ៩,២២០សន្លឹក។
- បានផ្តល់សេវាដឹកជញ្ជូនសម្រាប់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចុះបំពេញបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តទាំង ៨ ភូមិភាគ ចំនួន ៤៩លើក ស្មើនឹង ១៣៨នាក់។
- បានរៀបចំ បោសសម្អាត តុបតែងលម្អសាល តាំងលម្អផ្កាមុខអគារក្រហម និងសាលជំនួបភ្ញៀវ ព្រមទាំងផ្តល់សេវាបម្រើភេសជ្ជៈ អាហារសម្រន់ក្នុងកិច្ចប្រជុំ និងកម្មវិធីផ្សេងៗ ចំនួន ១២លើក ស្មើនឹង ៣៣៤នាក់។
- បានទទួលលិខិតចូល ចំនួន ១,៣៧៩ច្បាប់ និងបញ្ជូនលិខិតចេញទៅក្រសួង ស្ថាប័នពាក់ព័ន្ធនានា ចំនួន ៣៧០ច្បាប់។

- បានធ្វើលិខិតបេសកកម្មជូនសមាជិក សមាជិកាព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ២៦ច្បាប់ ស្មើនឹង ១១៤នាក់ និងលិខិតអនុញ្ញាតច្បាប់ជូនសមាជិក សមាជិកាព្រឹទ្ធសភា ចំនួន ១០ច្បាប់។
- បានចុះសួរសុខទុក្ខមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភាលំហែមាតុភាព ចំនួន ១នាក់។
- បានកែលម្អសួនច្បារ កាត់តម្រឹមស្មៅ មែកឈើ និងផ្កានានា ចំនួន ១៣លើក និងបានតាំងលម្អផ្កាស្បៃរឿង ក្រោមព្រះឆាយាល័ក្ខណ៍ **ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** នៅមុខស្ថាប័នព្រឹទ្ធសភា ចំនួន ២០០គុម្ព ដើម្បីអបអរសាទរព្រះរាជពិធី " **គ្រងព្រះបរមសិរីរាជសម្បត្តិរបស់ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** " ព្រមទាំងសម្អាតបរិស្ថាន អនាម័យ ក្នុងបរិវេណព្រឹទ្ធសភា ចំនួន ១៤លើក។
- បានធ្វើបញ្ជីស្ថិតិមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា រួមមាន៖
    - មន្ត្រីរាជការក្របខ័ណ្ឌ ចំនួន ៧១៤នាក់ (ប្រុស ៤២៣នាក់ ស្រី ២៩១នាក់)។
    - បុគ្គលិកជាប់កិច្ចសន្យា ចំនួន ៨៥នាក់ (ប្រុស ៤៩នាក់ ស្រី ៣៦នាក់)។
    - មន្ត្រីរាជការមានមុខតំណែងគ្រប់គ្រង ចំនួន ៤៩៣នាក់ (ប្រុស ៣០៦នាក់ ស្រី ១៨៧នាក់)។
    - មន្ត្រីរាជការស្ថិតក្នុងភាពទំនេរគ្មានបៀវត្ស ចំនួន ១១នាក់ និង
    - មន្ត្រីរាជការព្យួរនៅក្រៅក្របខ័ណ្ឌដើម ចំនួន ៣នាក់។
- បានធ្វើសេចក្តីសម្រេច ចំនួន ៣ច្បាប់ និងលិខិតបង្គាប់ការ ចំនួន ១ច្បាប់ ។
- បានធ្វើតារាងបញ្ជាក់ប្រាក់បៀវត្ស ប្រាក់បំណាច់ផ្សេងៗ លិខិតផ្តត់ផ្តង់ និងវិញ្ញាបនបត្របញ្ជាក់រយៈពេលបំពេញការងាររដ្ឋ ចំនួន ៤ច្បាប់។
- បានធ្វើបញ្ជីរាយនាមមន្ត្រីរាជការស្នើសុំប្រាក់វិភាជន៍គ្រួសារ (ប្រពន្ធ-កូន) ប្រចាំខែតុលា ឆ្នាំ២០២៤។
- បានបញ្ជូនមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៧៥នាក់ ចូលរួមវគ្គបណ្តុះបណ្តាលនៅក្នុងស្ថាប័នព្រឹទ្ធសភា ចំនួន ៤វគ្គ ស្តីពី៖
    - វគ្គ "ភាសាចិនថ្នាក់បឋមថ្មី" ។
    - វគ្គ "ភាសាចិនថ្នាក់បឋម" បន្តជំហានទី៨។
    - វគ្គ "ភាសាចិនថ្នាក់មធ្យម" បន្តជំហានទី៨ និង
    - វគ្គ "កិច្ចការសភា" ជំហានទី១០។
- បានធ្វើផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សរយៈពេល៦ឆ្នាំ (ឆ្នាំ២០២៤-២០៣០) នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បន្តតាមដាន ត្រួតពិនិត្យផែនការបណ្តុះបណ្តាល និងអភិវឌ្ឍន៍ធនធានមនុស្សឆ្នាំ២០២៥។
- ការងារសាងសង់សំណង់ថ្មីៗ ជួសជុលកែលម្អអគារ និងហេដ្ឋារចនាសម្ព័ន្ធផ្សេងៗ រួមមាន៖
    - បានប្តូរបិតកុងតាក់ទ័រសម្រាប់បញ្ជាភ្លើងជណ្តើរយន្ត នៅអគារថ្នាក់ដឹកនាំព្រឹទ្ធសភា។
    - បានប្តូរកញ្ចក់នៅសាលរង់ចាំស្លាបខាងកើត នៃសាលប្រជុំពេញអង្គព្រឹទ្ធសភា។
    - បានប្តូរអ្លូទ្វារកញ្ចក់នៅគណៈកម្មការទី១០ព្រឹទ្ធសភា។

- បានបង្រួមសួន និងពង្រីកផ្លូវ នៅមុខអគារក្រហមព្រឹទ្ធសភា ព្រមទាំងបានជួសជុល និងធ្វើគម្របលូថ្មី នៅខាងត្បូងខុទ្ទកាល័យសម្ដេចប្រធានព្រឹទ្ធសភា និង
- បានជួសជុលដំបូលស័ង្កសី នៅប៉ុស្ដិ៍យាម P4។

- បានជួសជុលកែលម្អហេដ្ឋារចនាសម្ព័ន្ធអគារ បណ្ដាញទឹក បណ្ដាញអគ្គិសនី ត្រួតពិនិត្យជណ្ដើរយន្ត សត្វកណ្ដៀរ រៀបចំ និងផ្លាស់ប្ដូរគ្រឿងអគ្គិសនី គ្រឿងអេឡិចត្រូនិច គ្រឿងសង្ហារិម ប្រមូលសម្ភារខូច បិទលេខកូដសម្ភារសារពើភណ្ឌ ប្រគល់ និងបំពាក់សម្ភារការិយាល័យជូនអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងជួសជុលហេដ្ឋារចនាសម្ព័ន្ធផ្សេងៗទៀតក្នុងបរិវេណព្រឹទ្ធសភា ចំនួន ១៧១គ្រឿង/លើក។
- បានធ្វើសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ នៅតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្ដីពី សកម្មភាព និងលទ្ធផលការងាររបស់ព្រឹទ្ធសភា នៅចន្លោះសម័យប្រជុំលើកទី១ និងលើកទី២ នីតិកាលទី៥។
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៤ ទូលថ្វាយ **ព្រះករុណាព្រះបាទសម្ដេចព្រះបរមនាថ នរោត្តម សីហមុនី** ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា។
- បានធ្វើបទបង្ហាញ និងរបាយការណ៍ស្ដីពី ការប្រជុំបូកសរុបលទ្ធផលការងាររបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៤ និង
- បានធ្វើរបាយការណ៍ស្ដីពី លទ្ធផលការងាររបស់ព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៤ ព្រមទាំងបានផ្សព្វផ្សាយលើគេហទំព័រព្រឹទ្ធសភា និងក្រសួង ស្ថាប័នពាក់ព័ន្ធនានា។

**៤.៣-ការងារសេវាច្បាប់៖**

- បានទទួលព្រះរាជក្រម ព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្ដីសម្រេច ប្រកាស សារាចរណែនាំ របាយការណ៍ សេចក្ដីជូនដំណឹង និងលិខិតផ្សេងៗ ចំនួន ៤ច្បាប់ ពីក្រសួង និងស្ថាប័ននានា។
- បានធ្វើកំណត់បង្ហាញជូនថ្នាក់ដឹកនាំព្រឹទ្ធសភា ចំនួន ៤លើក អំពីការប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥។
- បានធ្វើដីកាបញ្ជូន អំពីការចាប់ផ្ដើមសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ បញ្ជូនទៅអគ្គលេខាធិការដ្ឋានរដ្ឋសភា អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ និងទីស្ដីការគណៈរដ្ឋមន្ត្រី។
- បានតាមដានដំណើរការវិវឌ្ឍន៍សម័យប្រជុំរបស់រដ្ឋសភា។
- បានផ្ដល់សេវារដ្ឋបាល បច្ចេកទេស ព័ត៌មាន ពិធីការ ទំនាក់ទំនងការងារ ជូនគណៈកម្មការទាំង១០ និងក្រុមនានារបស់ព្រឹទ្ធសភា អញ្ជើញចុះបេសកកម្ម និងកម្មវិធីផ្សេងៗ ចំនួន ១៦២លើក។

- បានទាក់ទងជាមួយរដ្ឋបាលរាជធានី ខេត្ត ដើម្បីត្រៀមរៀបចំជូនថ្នាក់ដឹកនាំ អញ្ជើញចុះជួបសំណេះសំណាល សួរសុខទុក្ខក្រុមប្រឹក្សាឃុំ-សង្កាត់ និងប្រមូលព័ត៌មានថ្មីៗ ដើម្បីធ្វើបច្ចុប្បន្នភាពក្រុមប្រឹក្សាខណ្ឌ ក្រុង ស្រុក ឃុំ សង្កាត់ និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះបុគ្គលជាប់កាតព្វកិច្ចប្រកាសទ្រព្យសម្បត្តិ និងបំណុល ឆ្នាំ២០២៥ នៅព្រឹទ្ធសភា និងអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

**៤.៤-ការងារស្រាវជ្រាវ៖**

- បានសិក្សាស្រាវជ្រាវ និងកសាងជំនួយស្មារតីលើសេចក្តីព្រាងច្បាប់ ចំនួន ២ច្បាប់៖
    - សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់ និង
    - សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគី នៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិ សម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់ និង/ឬប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាន នៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ។
- បានតាមដាន និងសិក្សាស្រាវជ្រាវលើ៖
    - សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រង ឆ្នាំ២០២៥។
    - សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។
    - ការអនុវត្តការធ្វើកំណែទម្រង់គោលនយោបាយចំណូល-ចំណាយ។
    - វឌ្ឍនភាព នៃការអនុវត្តរបស់រាជរដ្ឋាភិបាលអំពីការធ្វើវិមជ្ឈការ និងវិសហមជ្ឈការក្នុងវិស័យនានា។
    - យុទ្ធសាស្ត្រស្តីពី ការគ្រប់គ្រងបំណុលសាធារណៈ ឆ្នាំ២០២៤-២០២៨។
    - ព្រឹត្តិបត្រស្ថិតិបំណុលសាធារណៈកម្ពុជា និងរបាយការណ៍របស់ធនាគារជាតិ នៃកម្ពុជា និង
    - របាយការណ៍និន្នាការសេដ្ឋកិច្ច សង្គម ប្រចាំខែ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។
- បានសិក្សា និងផ្តល់ជូននូវអត្ថបទស្រាវជ្រាវ ព្រមទាំងបានធ្វើបទបង្ហាញលើសេចក្តីព្រាងច្បាប់ ចំនួន ២ច្បាប់ ជូនគណៈកម្មការទី២ ទី៨ និងទី៩ ព្រឹទ្ធសភា។
- បានតាមដាន សិក្សាស្រាវជ្រាវ និងចងក្រងឯកសារគោលនយោបាយជាតិស្តីពី " គោលនយោបាយជាតិអេកូទេសចរណ៍ ឆ្នាំ២០១៩-២០៣០ "។
- បានស្រង់ឯកសារពីក្នុងរាជកិច្ច និងចាត់ថ្នាក់ទៅតាមវិស័យច្បាប់ និងលិខិតបទដ្ឋានគតិយុត្ត (រាជកិច្ចពីលេខ ៦៨-៧៥ ឆ្នាំ២០២៣)។
- បន្តចងក្រងទិន្នន័យលិខិតបទដ្ឋានគតិយុត្តតាមវិស័យរបស់គណៈកម្មការនានា។
- បានផលិតព្រឹត្តិបត្រព័ត៌មានថវិកា និងសេដ្ឋកិច្ច ប្រចាំសប្តាហ៍ក្នុងខែតុលា ឆ្នាំ២០២៤ ចំនួន ៤ច្បាប់។

- បានបកប្រែ និងសង្ខេបព័ត៌មានសភាបញ្ចូលក្នុងសម្រង់សង្ខេបព័ត៌មានសំខាន់ៗប្រចាំថ្ងៃ ចំនួន ២២៩ព័ត៌មាន និង
- បានបញ្ចូលទិន្នន័យថវិកាចំណូល-ចំណាយក្នុងតារាងប្រតិបត្តិការហិរញ្ញវត្ថុ និងសេដ្ឋកិច្ច (TOFE) ប្រចាំខែ ក្នុងឆ្នាំ២០២៤ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

**៤.៩-ការងារព័ត៌មាន និងទំនាក់ទំនងសាធារណៈ៖**

- បានផលិត និងផ្សព្វផ្សាយខ្សែវីដេអូព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា ចំនួន ១១លើក។
- បានថត និងផ្សព្វផ្សាយព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងសកម្មភាពការងាររបស់ព្រឹទ្ធសភា និង អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា តាមប្រព័ន្ធ Facebook, Instagram, X ( Former Twitter ), Youtube និងTiktok ចំនួន ៩៧៥លើក។
- បានបញ្ចូលព័ត៌មានស្ដីពី សកម្មភាពការងាររបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ព្រមទាំងលទ្ធផលការងាររបស់ព្រឹទ្ធសភា លើគេហទំព័រព្រឹទ្ធសភា ចំនួន ២៥៣ប្រធានបទ។
- បានប្រមូល និងផ្សព្វផ្សាយព័ត៌មានក្នុងឆានែលតេឡេក្រាម ព័ត៌មានប្រចាំថ្ងៃ ចំនួន ១,៣០១ ប្រធានបទ។
- បានអញ្ជើញអ្នកព័ត៌មានទូរទស្សន៍ជាតិកម្ពុជាចូលយកព័ត៌មានក្នុងជំនួបសម្ដែងការគួរសម និង ពិភាក្សាការងារជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន ៧លើក។
- បានតាំងពិព័រណ៍រូបភាពសកម្មភាពរបស់ថ្នាក់ដឹកនាំព្រឹទ្ធសភា សមាជិក សមាជិកាគណៈកម្មការ ទាំង១០ ក្រុមភូមិភាគទាំង៨ និងក្រុមយន្តការនានារបស់ព្រឹទ្ធសភា នៅខ្លោងទ្វារធំព្រឹទ្ធសភា ចំនួន ១២លើក។
- បានផលិត និងផ្សព្វផ្សាយទស្សនាវដ្ដីប្រចាំខែតុលា ឆ្នាំ២០២៤។
- បានផលិតព្រឹត្តិបត្រស្ដីពី បច្ចេកវិទ្យាព័ត៌មាន ប្រចាំខែតុលា ឆ្នាំ២០២៤ ចំនួន ១ច្បាប់។
- បានចុះត្រួតពិនិត្យ តាមដានប្រព័ន្ធណេតវើក អ៊ីនធឺណែត ពង្រឹងពង្រីកការផ្គត់ផ្គង់ និងជួសជុល ឧបករណ៍ សម្ភារបរិក្ខារបច្ចេកទេស ព្រមទាំងដោះស្រាយបញ្ហាផ្សេងៗដែលពាក់ព័ន្ធនឹងជំនាញ បច្ចេកវិទ្យាព័ត៌មាន ចំនួន ១២៨គ្រឿង/លើក។
- បានរៀបចំប្រព័ន្ធស្ទូឌីយ៉ូ ប្រព័ន្ធសំឡេង ប្រព័ន្ធមេក្រូហ្វូន ប្រព័ន្ធរូបភាព ប្រព័ន្ធកាមេរ៉ា និង ប្រព័ន្ធប្រជុំនិម្មិត ឬប្រព័ន្ធប្រជុំពីចម្ងាយ( Digital ) ក្នុងជំនួបសម្ដែងការគួរសម និងពិភាក្សាការងារ ជាមួយភ្ញៀវជាតិ-អន្តរជាតិ ព្រមទាំងកិច្ចប្រជុំសំខាន់ៗរបស់ព្រឹទ្ធសភា ចំនួន ២៨លើក។

- បានរៀបចំកម្មវិធីទទួលពាក្យបណ្ដឹងព្រឹទ្ធសភាអេឡិចត្រូនិច (Mobile Application) និងយុទ្ធសាស្ត្រផ្សព្វផ្សាយ។
- បានរៀបចំបំប្លែងកាសែតវីដេអូចាស់ៗរបស់ព្រឹទ្ធសភា ទៅជាប្រភេទវីដេអូឌីជីថល ដើម្បីរក្សាទុកក្នុងប្រព័ន្ធទិន្នន័យ។
- បានទទួលឯកសារ និងសៀវភៅជំនាញផ្សេងៗ ចំនួន ២០ក្បាល។
- បានផ្សព្វផ្សាយឯកសាររបស់ព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ឯកសារច្បាប់ ឯកសារជំនាញផ្សេងៗ និងសៀវភៅជា E-Book តាម www.elibrary.senate.gov.kh ចំនួន ៧,៤០៤ក្បាល ដែលមានសាធារណជនចូលអាន ចំនួន ១,០១៨នាក់ និង
- បានផ្សព្វផ្សាយឯកសារ និងសៀវភៅដែលមាននៅក្នុងបណ្ណាល័យព្រឹទ្ធសភា ក្នុងផេក TikTok របស់បណ្ណាល័យព្រឹទ្ធសភា (មាន Follower ចំនួន ២៤នាក់ និងអ្នក Like ចំនួន ៣៥នាក់)។

### ៤.៦-ការងារពិធីការ និងទំនាក់ទំនងអន្តរជាតិ៖

- បានរៀបចំចាត់ចែង និងសម្របសម្រួលជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចូលរួមកិច្ចប្រជុំ ជំនួបសម្ដែងការគួរសម ពិភាក្សាការងារ និងពិធីផ្សេងៗ ចំនួន ៣០លើក។
- បានរៀបចំសារលិខិតថ្វាយព្រះពរ និងជូនពរ លិខិតរំលែកទុក្ខ និងលិខិតអបអរសាទរ ទូលថ្វាយ **ព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា** ព្រមទាំងឥស្សរជនជាន់ខ្ពស់ ថ្នាក់ដឹកនាំតាមក្រសួងស្ថាប័ននានា ចំនួន ១៦លិខិត។
- បានរៀបចំបែបបទស្នើសុំលិខិតឆ្លងដែនការទូតថ្មី ជូនសមាជិកព្រឹទ្ធសភា និងមន្ត្រីរាជការ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ចំនួន ៣នាក់។
- បានកសាងឯកសារជំនួយស្មារតីលើប្រធានបទនានា ចំនួន ២ច្បាប់។
- បានផលិត និងផ្សព្វផ្សាយព្រឹត្តិបត្រព័ត៌មានកិច្ចការអន្តរជាតិប្រចាំខែតុលា ឆ្នាំ២០២៤ ចំនួន ១ច្បាប់។
- បានតាមដាន និងចងក្រងសេចក្ដីប្រកាសព័ត៌មាន និងសេចក្ដីថ្លែងការណ៍របស់ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ ចំនួន ៨ច្បាប់ និង
- បានតុបតែងលម្អបំភ្លឺភ្លើងពណ៌នៅខាងមុខស្ថាប័នព្រឹទ្ធសភា និងចងបដា ពាក្យស្លោក ក្នុងពិធីបុណ្យផ្សេងៗ ចំនួន ២លើក។

### ៤.៧-ការងារអគ្គាធិការដ្ឋាន៖

- បានសិក្សារបាយការណ៍ និងកម្រងសំណួរ អំពីការងារសង្គមកិច្ច និងការផ្ដល់សេវារបស់នាយកដ្ឋាននានា ចំណុះអគ្គនាយកដ្ឋានទាំង៥ នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ប្រចាំខែតុលា ឆ្នាំ២០២៤ ចំនួន ២២លើក។

- បានប្រមូល និងធ្វើរបាយការណ៍ជាមួយនាយកដ្ឋានផែនការ និងសរុប នាយកដ្ឋានគ្រប់គ្រងបុគ្គលិក នាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងបណ្ណសារដ្ឋាន ស្តីពី ការអនុវត្តផែនការការងារ និងគោលនយោបាយនានារបស់អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។
- បានធ្វើរបាយការណ៍ស្តីពី លទ្ធផលការងាររបស់នាយកដ្ឋានត្រួតពិនិត្យការងារសង្គមកិច្ច និងការផ្តល់សេវាប្រចាំខែតុលា ឆ្នាំ២០២៤។
- បានចុះត្រួតពិនិត្យវត្តមានជាក់ស្តែងតាមនាយកដ្ឋាននានា ប្រចាំខែតុលា ចំនួន ២លើក ដើម្បីផ្ទៀងផ្ទាត់បញ្ជីវត្តមានដែលនាយកដ្ឋានចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានជាប្រចាំថ្ងៃ។
- បានបូកសរុប និងធ្វើរបាយការណ៍សម្រង់វត្តមានប្រចាំថ្ងៃ ចំនួន ៣៤លើក ប្រចាំសប្តាហ៍ ចំនួន ៤លើក និងប្រចាំខែតុលា ឆ្នាំ២០២៤ ដែលគ្រប់អង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា បានបញ្ជូនមកអគ្គាធិការដ្ឋានជាប្រចាំថ្ងៃ។
- បានចុះត្រួតពិនិត្យ និងធ្វើរបាយការណ៍ស្តីពី បរិស្ថាន អនាម័យ ការខូចខាតសម្ភារតាមអគារ និងសណ្តាប់ធ្នាប់នៃការចតយានយន្តក្នុងបរិវេណព្រឹទ្ធសភា និង
- បានធ្វើបច្ចុប្បន្នភាពបញ្ជីឈ្មោះមន្ត្រីរាជការតាមអង្គភាពចំណុះអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

## II-ទិសដៅការងារខែវិច្ឆិកា ឆ្នាំ២០២៤

### ១- មុខងារនីតិកម្ម

- ត្រៀមរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងប្រជុំពេញអង្គព្រឹទ្ធសភា នីតិកាលទី៥ ដើម្បីពិនិត្យ ហើយឱ្យយោបល់លើសេចក្តីព្រាងច្បាប់ ចំនួន ៤ច្បាប់៖
    - ១- សេចក្តីព្រាងច្បាប់ស្តីពី ប្រព័ន្ធទឹកកខ្វក់
    - ២- សេចក្តីព្រាងច្បាប់ស្តីពី ការអនុម័តយល់ព្រមឱ្យព្រះរាជាណាចក្រកម្ពុជា ចូលជាភាគីនៃកិច្ចព្រមព្រៀងស្តីពី ការទទួលយកបទប្បញ្ញត្តិបច្ចេកទេសរួមនៃអង្គការសហប្រជាជាតិសម្រាប់យានយន្ត បរិក្ខារ និងគ្រឿងបន្លាស់ដែលអាចបំពាក់ និង/ឬប្រើប្រាស់ទៅលើយានយន្ត និងលក្ខខណ្ឌសម្រាប់ការទទួលស្គាល់ទៅវិញទៅមកនៃការផ្តល់អនុលោមភាពដោយឈរលើមូលដ្ឋាន នៃបទប្បញ្ញត្តិអង្គការសហប្រជាជាតិ
    - ៣- សេចក្តីព្រាងច្បាប់ស្តីពី ហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៥ និង
    - ៤-សេចក្តីព្រាងច្បាប់ស្តីពី ការទូទាត់ថវិកាទូទៅរបស់រដ្ឋសម្រាប់ការគ្រប់គ្រងឆ្នាំ២០២៣។

### ២-មុខងារតាមដានការអនុវត្តច្បាប់ និងគោលនយោបាយនានា

- ត្រៀមសហការ និងសម្របសម្រួលការងារជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា ជួបសវនាការតាមផែនការការងារថ្មីជាមួយក្រសួង ស្ថាប័ន និងការចុះបេសកកម្ម នៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។

## ៣- មុខងារតំណាង

- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា អញ្ជើញចុះជួបសំណេះសំណាល សាកសួរសុខទុក្ខប្រជាពលរដ្ឋនៅមូលដ្ឋាន ពិភាក្សាការងារជាមួយអាជ្ញាធរដែនដី ចុះពិនិត្យវឌ្ឍនភាព នៃការអភិវឌ្ឍ នៅថ្នាក់ក្រោមជាតិ ចូលរួមពិធីសាសនា និងពិធីផ្លូវការផ្សេងៗនៅរាជធានីភ្នំពេញ និងតាមបណ្តាខេត្តនានា។
- ត្រៀមផ្តល់សេវាជូនក្រុមសមាជិកព្រឹទ្ធសភាប្រចាំភូមិភាគទី៤ និងទី៦ សហការជាមួយក្រុមគ្រូពេទ្យស្ម័គ្រចិត្ត នៃសមាគមបេសកកម្មមនុស្សធម៌នៅកម្ពុជា (AMH) ចុះពិនិត្យ និងព្យាបាលជំងឺទូទៅជូនប្រជាពលរដ្ឋ នៅស្រុកប្រាសាទ ខេត្តសៀមរាប និងស្រុកកំពង់រោទិ៍ ស្រុករំដួល ក្រុងស្វាយរៀង ខេត្តស្វាយរៀង។
- ត្រៀមរៀបចំជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អញ្ជើញចូលរួម៖
  - ពិធីបុណ្យឯករាជ្យជាតិ ៩ វិច្ឆិកា និង
  - ព្រះរាជពិធីបុណ្យអុំទូក បណ្តែតប្រទីប និងសំពះព្រះខែ អកអំបុក ឆ្នាំ២០២៤។

## ៤- មុខងារសហប្រតិបត្តិការអន្តរជាតិ

- ផ្តល់សេវាចាំបាច់បម្រើការងារសហប្រតិបត្តិការតំបន់ និងអន្តរជាតិ ការចូលរួមមហាសន្និបាត សិក្ខាសាលា វេទិកានានា កម្មវិធីជំនួប កម្មវិធីផ្លូវការ និងកិច្ចសហប្រតិបត្តិការជាមួយដៃគូសំខាន់ៗ។
- ត្រៀមរៀបចំជូនគណៈប្រតិភូជាន់ខ្ពស់ព្រឹទ្ធសភា៖
  - អញ្ជើញទៅបំពេញទស្សនកិច្ចការងារ នៅរដ្ឋកាតា សាធារណរដ្ឋតួកគី និងសាធារណរដ្ឋប្រជាមានិតចិន។
  - អញ្ជើញចូលរួមប្រជុំពេញអង្គលើកទី១១ នៃសភាអន្តរជាតិ ដើម្បីភាពអត់ឱន និងសន្តិភាព (IPTP) ដែលកម្ពុជានឹងធ្វើជាម្ចាស់ផ្ទះ នាខែវិច្ឆិកា ឆ្នាំ២០២៤ និង
  - ត្រៀមធ្វើជាម្ចាស់ផ្ទះសន្និសីទអន្តរជាតិគណបក្សនយោបាយ នៅអាស៊ី-ប៉ាស៊ីហ្វិក ដែលមានជាង៣៨០គណបក្ស និងមកពីជាង៥២ប្រទេសចូលរួម។

## ៥- មុខងារអភិវឌ្ឍន៍ស្ថាប័ន

- បន្តអភិវឌ្ឍន៍ហេដ្ឋារចនាសម្ព័ន្ធនានារួមមាន ការសាងសង់អគារថ្មី ការជួសជុល ថែទាំ កែលម្អបរិស្ថានអនាម័យ សួនច្បារ ប្រព័ន្ធអគ្គិសនី ប្រព័ន្ធទឹក ប្រព័ន្ធលូ ប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន និងប្រព័ន្ធសន្តិសុខផ្ទៃក្នុងព្រឹទ្ធសភា ប្រកបដោយសុខសុវត្ថិភាព។
- បន្តផ្តល់សេវាផ្គត់ផ្គង់សម្ភារ ថវិកា មធ្យោបាយដឹកជញ្ជូន និងសេវាសំខាន់ៗផ្សេងទៀត ជូនថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បំពេញមុខងាររបស់ខ្លួនឱ្យបានទាន់ពេលវេលា និងល្អប្រសើរ។
- បន្តការចុះសួរសុខទុក្ខនិវត្តជន និងមន្ត្រីលំហែមាតុភាព នៃអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា។

- ត្រៀមរៀបចំប្រទីបរបស់ព្រឹទ្ធសភា និងគ្រឿងឧបភោគ បរិភោគ សម្ភារ និងថវិកា សម្រាប់ថ្នាក់ដឹកនាំព្រឹទ្ធសភា ឧបត្ថម្ភកីឡាករអុំទូក និងគណៈកម្មការនានា និង
- ត្រៀមបើកវគ្គបណ្តុះបណ្តាលស្តីពី វប្បធម៌សភា និងវប្បធម៌នយោបាយ និងវគ្គគ្រូបង្គោល (TOT) ស្តីពី វិធីសាស្ត្រក្នុងការផលិតឯកសារស្រាវជ្រាវសង្ខេប ។

## III-សេចក្តីសន្និដ្ឋាន

ខែតុលា ជាខែទី១ នៃការចាប់ផ្តើមសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥។ ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា បានបន្តខិតខំបំពេញមុខងាររបស់ខ្លួនយ៉ាងសកម្ម។

អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា មានភាពមមាញឹកខ្លាំងលើការផ្តល់សេវាលើមុខងារតំណាង និងការងារការទូតសភាទាំងក្នុងក្របខ័ណ្ឌស្ថាប័ន និងក្របខ័ណ្ឌអន្តរជាតិតាមរយៈដំណើរទស្សនកិច្ចការងារ និងចូលរួមមហាសន្និបាតរបស់ថ្នាក់ដឹកនាំ សមាជិក សមាជិកាព្រឹទ្ធសភា និងថ្នាក់ដឹកនាំអគ្គលេខាធិការដ្ឋានព្រឹទ្ធសភា នៅក្រៅប្រទេស។

ស្របពេលជាមួយគ្នានេះផងដែរ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា ក៏បានរៀបចំប្រជុំគណៈកម្មាធិការអចិន្ត្រៃយ៍ និងបើកសម័យប្រជុំលើកទី២ព្រឹទ្ធសភា នីតិកាលទី៥ ប្រព្រឹត្តទៅបានល្អប្រសើរ។

ថ្ងៃចន្ទ ៨ រោច ខែ អស្សុជ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨

រាជធានីភ្នំពេញ ថ្ងៃទី២៨ ខែ [illegible] ឆ្នាំ២០២៤

**អគ្គលេខាធិការ**

**ឡាយ សំគុល**